អង្គការទិន្នន័យអំពីការអភិវឌ្ឍ
Open Development Cambodia Organization

www.opendevcam.net
OpenDevCam
@OpenDevCam
(+855) 23 902 196
contact@opendevcam.net

# ការប្រកួតសំណេរយុវជន ក្រោមប្រធានបទ

## “ជនជាតិដើមភាគតិច និងធនធានធម្មជាតិ”

អង្គការទិន្នន័យអំពីការអភិវឌ្ឍ (អូឌីស៊ី) គឺជាវេទិកាទិន្នន័យបើកទូលាយឈានមុខគេនៅកម្ពុជា ដែលផ្តល់ទិន្នន័យត្រឹមត្រូវ និងថ្មីបំផុត ហើយព័ត៌មានទាក់ទងនឹងបញ្ហាសេដ្ឋកិច្ចសង្គម និងបរិស្ថានត្រូវបានប្រមូលផ្តុំ ហើយផ្សព្វផ្សាយជាសាធារណៈនៅលើបណ្តាញអ៊ីនធឺណែត។ អូឌីស៊ីលើកកម្ពស់ការប្រើប្រាស់ទិន្នន័យត្រឹមត្រូវសម្រាប់ដំណើរការសម្រេចចិត្តផ្អែកលើភស្តុតាង និងតម្លាភាពឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាព។ អូឌីស៊ីផ្តល់នូវព័ត៌មាន និងទិន្នន័យពាក់ព័ន្ធជាច្រើនរួមមាន ឧស្សាហកម្មនិស្សារណកម្ម ដីធ្លី បរិស្ថាន និងធនធានធម្មជាតិ ដីសមូហភាពជនជាតិដើមភាគតិច ព្រមទាំងទិន្នន័យ និងព័ត៌មានផ្សេងទៀត។ ជាផ្នែកមួយនៃការបង្ហាញពីទស្សនៈរបស់យុវជនក្នុងការគ្រប់គ្រងធនធានធម្មជាតិដែលផ្សារភ្ជាប់ជាមួយនឹងជនជាតិដើមភាគតិច អង្គការអូឌីស៊ីរៀបចំការប្រកួតសំណេរនេះឡើងដើម្បីលើកទឹកចិត្តឱ្យយុវជនទាំងអស់ចូលរួមបង្ហាញពីការយល់ឃើញនិងទស្សនៈប្រកបដោយបរិយាបន្ន និងការចូលរួម។ ការសរសេរអត្ថបទសំណេរអាចឱ្យយុវជនឆ្លុះបញ្ចាំង និងស្វែងយល់ដោយមានការគិតពិចារណាចំពោះប្រធានបទ “ជនជាតិដើមភាគតិច និងធនធានធម្មជាតិ” ដើម្បីបញ្ចេញគំនិតរបស់ពួកគេឱ្យកាន់តែច្បាស់លាស់។

ការប្រកួតសំណេរយុវជនក្រោមប្រធានបទ **“ជនជាតិដើមភាគតិច និងធនធានធម្មជាតិ”** ពិតជាមានសារៈសំខាន់ណាស់ ព្រោះយើងអាចបង្កើតជាវេទិកាមួយសម្រាប់យុវជនដើម្បីបង្ហាញពីសម្លេងឬទស្សនៈរបស់ពួកគេ ដើម្បីចូលរួមក្នុងការបង្ហាញពីបញ្ហាក៏ដូចជាដំណោះស្រាយប្រសព្វគ្នានៃសិទ្ធិរបស់ជនជាតិដើមភាគតិច សិទ្ធិដីធ្លីនិងធនធានធម្មជាតិ និងនិរន្តរភាពបរិស្ថាន។ សហគមន៍ជនជាតិដើមភាគតិចដើរតួនាទីយ៉ាងសំខាន់ក្នុងការការពារប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ដែលជារឿយៗពួកគាត់ដើរតួនាទីជាអ្នកការពារជួរមុខប្រឆាំងនឹងការកាប់បំផ្លាញព្រៃឈើ និងភាពវិចវិលនៃបរិស្ថាន។ ទោះជាយ៉ាងណាក៏ដោយ ពួកគាត់ក៏បានប្រឈមនូវបញ្ហាមួយចំនួននាពេលបច្ចុប្បន្ននេះ ជាពិសេសការចុះបញ្ជីដីសមូហភាពជនជាតិដើមភាគតិច ការប្រែប្រួលអាកាសធាតុ ការប្រើប្រាស់ដី និងបញ្ហាផ្សេងទៀត។ តាមរយៈការលើកទឹកចិត្តយុវជនឱ្យឆ្លុះបញ្ចាំងពីបញ្ហាប្រឈមទាំងនេះ ការប្រកួតសំណេរនេះនឹងលើកកម្ពស់ការយល់ដឹងរបស់យុវជនពាក់ព័ន្ធនឹងការផ្សារភ្ជាប់របស់ជនជាតិដើមភាគតិចនិងធនធានធម្មជាតិនៅប្រទេសកម្ពុជា។

### ១. គោលបំណង

ការប្រកួតសំណេរយុវជននេះត្រូវបានរៀបចំឡើងដើម្បីបង្ហាញពីទស្សនៈ និងការគិតគូរដល់ទំនាក់ទំនងរបស់ជនជាតិដើមភាគតិចនៅកម្ពុជាជាមួយនឹងធនធានធម្មជាតិ ដីធ្លី និងការប្រែប្រួលអាកាសធាតុ។ សកម្មភាពនេះក៏មានគោលបំណងលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីសិទ្ធិរបស់ជនជាតិដើមភាគតិច និងបញ្ហាដែលសហគមន៍កំពុងតែជួបប្រទះ និងលើកទឹកចិត្តដល់ការស្វែងរកដំណោះស្រាយរួម។

www.opendevcam.net
OpenDevCam
@OpenDevCam
(+855) 23 902 196
contact@opendevcam.net

## ២. រង្វាន់ជ័យលាភី

### ក. ជ័យលាភីលេខ ១

- ថវិកាចំនួន ១.០០០.០០០ រៀល
- កាដូរអនុស្សាវរីយ
- វិញ្ញាបនបត្រនៃការកោតសរសើរ
- អត្ថបទសំណេរនឹងត្រូវបានបោះពុម្ពផ្សាយនៅលើគេហទំព័រអង្គការអូឌីស៊ី និងតាមប្រព័ន្ធផ្សព្វផ្សាយ ព្រមទាំងបោះពុម្ពផ្សាយក្នុងសៀវភៅសំណេរ

### ខ. ជ័យលាភីលេខ ២

- ថវិកាចំនួន ៨០០.០០០ រៀល
- កាដូរអនុស្សាវរីយ
- វិញ្ញាបនបត្រនៃការកោតសរសើរ
- អត្ថបទសំណេរនឹងត្រូវបានបោះពុម្ពផ្សាយនៅលើគេហទំព័រអង្គការអូឌីស៊ី និងតាមប្រព័ន្ធផ្សព្វផ្សាយ ព្រមទាំងបោះពុម្ពផ្សាយក្នុងសៀវភៅសំណេរ

### គ. ជ័យលាភីលេខ ៣

- ថវិកាចំនួន ៦០០.០០០ រៀល
- កាដូរអនុស្សាវរីយ
- វិញ្ញាបនបត្រនៃការកោតសរសើរ
- អត្ថបទសំណេរនឹងត្រូវបានបោះពុម្ពផ្សាយនៅលើគេហទំព័រអង្គការអូឌីស៊ី និងតាមប្រព័ន្ធផ្សព្វផ្សាយ ព្រមទាំងបោះពុម្ពផ្សាយក្នុងសៀវភៅសំណេរ

### ឃ. ជ័យលាភីលេខ ៤

- ថវិកាចំនួន ៤០០.០០០ រៀល
- កាដូរអនុស្សាវរីយ
- វិញ្ញាបនបត្រនៃការកោតសរសើរ
- អត្ថបទសំណេរនឹងត្រូវបានបោះពុម្ពផ្សាយនៅលើគេហទំព័រអង្គការអូឌីស៊ី និងតាមប្រព័ន្ធផ្សព្វផ្សាយ ព្រមទាំងបោះពុម្ពផ្សាយក្នុងសៀវភៅសំណេរ

### ង. ជ័យលាភីលេខ ៥

- ថវិកាចំនួន ២០០.០០០ រៀល
- កាដូរអនុស្សាវរីយ
- វិញ្ញាបនបត្រនៃការកោតសរសើរ
- អត្ថបទសំណេរនឹងត្រូវបានបោះពុម្ពផ្សាយនៅលើគេហទំព័រអង្គការអូឌីស៊ី និងតាមប្រព័ន្ធផ្សព្វផ្សាយ ព្រមទាំងបោះពុម្ពផ្សាយក្នុងសៀវភៅសំណេរ

ច. អ្នកដែលបានជាប់ក្នុងជុំទី ១ និងមិនទទួលបានជ័យលាភីទាំង ៥ ខាងលើ

- កាដូរអនុស្សាវរីយ
- វិញ្ញាបនបត្រនៃការចូលរួម
- អត្ថបទសំណេរនឹងត្រូវបានបោះពុម្ពផ្សាយនៅលើគេហទំព័រអង្គការអូឌីស៊ី និងតាមប្រព័ន្ធផ្សព្វផ្សាយ ព្រមទាំងបោះពុម្ពផ្សាយក្នុងសៀវភៅសំណេរ

## ៣. លក្ខខណ្ឌ និងបែបបទនៃការចូលរួម

- ជាជនជាតិខ្មែរ ជនជាតិដើមភាគតិច ឬជនជាតិភាគតិច មានអាយុមិនលើសពី ២៥ឆ្នាំ (បេក្ខភាពជនជាតិដើមភាគតិច ជនដែលមានពិការភាព ត្រូវបានលើកទឹកចិត្តឱ្យចូលរួម)
- អត្ថបទសំណេរត្រូវតែសរសេរដោយអ្នកចូលរួមប្រកួតផ្ទាល់ មិនចម្លងពីអ្នកដទៃ ហើយសំណេរធ្វើឡើងសម្រាប់តែគោលបំណងនៃការប្រកួតនេះតែប៉ុណ្ណោះ
- អត្ថបទដែលផ្ញើមកត្រូវសរសេរជាភាសាខ្មែរ (សរសេរដោយដៃ ឬសរសេរដោយប្រើប្រាស់កុំព្យូទ័រ)
  - បើសិនជាសរសេរដោយដៃ ត្រូវផ្ញើអត្ថបទសំណេរនេះមកកាន់ការិយាល័យអូឌីស៊ីនៅរាជធានីភ្នំពេញ ហើយចំពោះអ្នកនៅខេត្តព្រះវិហារ អាចផ្ញើអត្ថបទសំណេរមកកាន់បណ្ណាល័យអ្នកប្រយុទ្ធ ដែលស្ថិតនៅសង្កាត់ប៉ាល់ហាល ក្រុងព្រះវិហារ។
  - បើសិនជាសរសេរដោយប្រើប្រាស់កុំព្យូទ័រ សូមផ្ញើអត្ថបទសំណេរមកកាន់៖ https://docs.google.com/forms/d/e/1FAIpQLSeh8rsZAg2RaUrtS0u2-Vc7zXadBMiAh-QirEQM2Je99xaUlQ/viewform
- អត្ថបទសំណេរដែលត្រូវបានជ្រើសរើសនៅក្នុងជុំទី១៖ ម្ចាស់អត្ថបទសំណេរត្រូវថតវីដេអូ (៣-៥នាទី) និយាយពីអត្ថបទសំណេរនោះ ហើយផ្ញើមកកាន់អូឌីស៊ី។
- សម្រាប់សំណួរនានាសូមទំនាក់ទំនងមកអូឌីស៊ីតាមរយៈ https://www.facebook.com/OpenDevCam

## ៤. ទម្រង់នៃសំណេរ

- ព័ត៌មានទំនាក់ទំនង៖ ឈ្មោះម្ចាស់សំណេរ ស្ថាប័ន តួនាទី លេខទូរស័ព្ទ និងអ៊ីម៉ែល (បើសិនមាន)
- ភាសា៖ ខេមរភាសា
- ទំហំ៖ សម្រាប់អ្នកប្រើប្រាស់កុំព្យូទ័រ ត្រូវប្រើទំហំក្រដាស A4 ដែលមានដាយទំព័រ ១អ៊ីញ និងទំហំអក្សរ ១១ Khmer OS Siem Reap)
- ប្រវែងសំណេរ៖ ៣ ទៅ ៦ ទំព័រ (Single Space)

## ៥. ការដាក់ពិន្ទុ

អត្ថបទសំណេរនឹងត្រូវធ្វើការវាយតម្លៃដោយគណកម្មាធិការដែលមានជំនាញ និងបទពិសោធន៍ក្នុងការសិក្សាស្រាវជ្រាវ សរសេរកិច្ចការស្រាវជ្រាវ និងធ្វើការសកម្មក្នុងប្រធានបទជនជាតិដើមភាគតិច និងធនធានធម្មជាតិ។

ការដាក់ពិន្ទុអត្ថបទសំណេរនឹងត្រូវបានអនុវត្តន៍ទៅតាមលក្ខខណ្ឌដូចខាងក្រោម៖

www.opendevcam.net
OpenDevCam
@OpenDevCam
(+855) 23 902 196
contact@opendevcam.net

- (១០ពិន្ទុ) ការរៀបចំ៖ តើអត្ថបទគោរពតាមទម្រង់នៃការសរសេរដែរឬទេ?
- (៣០ពិន្ទុ) ភាពច្បាស់លាស់៖ តើគោលគំនិតនៅក្នុងអត្ថបទមានភាពច្បាស់លាស់ដែរឬទេ?
- (៣០ពិន្ទុ) ការយល់ដឹង៖ តើអត្ថបទសំណេរបង្ហាញពីប្រធានបទដែលបានកំណត់ដែរឬទេ?
- (៣០ពិន្ទុ) ភាពត្រឹមត្រូវ៖ តើអត្ថន័យដែលបានលើកឡើងនៅក្នុងអត្ថបទសំណេរពិតជាបង្ហាញពីភាពទិដ្ឋភាពជាក់ស្តែង និងត្រឹមត្រូវដែរឬទេ?

## ៦. កាលបរិច្ឆេទ

- បើកទទួលពាក្យ៖ **ថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០២៤**
- បិទទទួលអត្ថបទសំណេរ៖ **ថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ២០២៤**
- ប្រកាសអត្ថបទសំណេរជ្រើសរើសសម្រាប់ជុំទី១ ចំនួន ១៥នាក់៖ **ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០២៤**
- បិទទទួលយកវីដេអូណែនាំពីសំណេរ (សម្រាប់សំណេរជាប់ជុំទី១)៖ **ថ្ងៃទី ១០ ខែធ្នូ ឆ្នាំ២០២៤**
- ប្រកាសលទ្ធផលសម្រេច (ជ័យលាភី ៥នាក់)៖ **ថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០២៤**